**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តសៀមរាប**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ០១៣ គល.សរ

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ថ្ងៃ............ខែ......ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ខេត្តសៀមរាបថ្ងៃទី...... ខែ...... ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់ឆ្នាំ២០១៩ ជូនរដ្ឋបាលខេត្តសៀមរាប

រដ្ឋបាលខេត្តសៀមរាបសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/ សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថាៈរដ្ឋបាលខេត្តសៀមរាបនឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈសម្រាប់ឆ្នាំ២០១៩ ជូនរដ្ឋបាលខេត្តសៀមរាប ។ ជាមួយគ្នានេះដែរ រដ្ឋបាលខេត្តបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/ សហគ្រាសដើម្បីបំពេញនិងចូលរួមដេញថ្លៃដែលឯកសារទាំងនេះ មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តសៀមរាប ដែលមានអាសយដ្ឋាននៅ សាលាខេត្តសៀមរាបចាប់ពីថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ: 063 765 590 ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ៩:០០ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៩ ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោង ៩:០៣ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**ប្រធានគណៈកម្មាធិការលទ្ធកម្មខេត្ត**

ឌៀ សិហា

ចម្លងជូន ÷
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ "កាលប្បវត្តិ"

ឯកសារដេញថ្លៃលទ្ធកម្មទំនិញ ទំព័រ 3/20